**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧០...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ៣២ សសរ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១
## ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា "ក.អ.ក" មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម ជិន ប៊ុនស៊ាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួង រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| ១៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង | សមាជិក |
| ២០- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង | សមាជិក |
| ២១- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង | សមាជិក |
| ២២- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង | សមាជិក |
| ២៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

រដ្ឋមន្ត្រី ឬប្រធានស្ថាប័នឯទៀត នៃរាជរដ្ឋាភិបាល ត្រូវចូលរួមក្នុងការប្រជុំរបស់ "ក.អ.ក" តាមការអញ្ជើញរបស់ប្រធាន។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួន ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សា និងការសម្រេច។

**មាត្រា២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ "គ.ស.ព" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៤- អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក"។

**មាត្រា៣ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងអគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានអគ្គលេខាធិការរងមួយចំនួនរៀងៗខ្លួនសម្រាប់ជាជំនួយការក្នុងការងារ។ អគ្គលេខាធិការរងនីមួយៗ ត្រូវបំពេញកិច្ចការតាមភារកិច្ចដែលអគ្គលេខាធិការប្រគល់ឱ្យ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ។ អគ្គលេខាធិការមួយរូបៗត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន។

**មាត្រា៤ .-**

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ

២- ផ្នែកឯកសារ និងគ្រប់គ្រងព័ត៌មាន

៣- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ល។)

៦- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និងបណ្តាស្ថាប័ននៃអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកគ្រប់គ្រងសម្របសម្រួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោងសហប្រតិបត្តិការ

៩- ផ្នែកភាពជាដៃគូ និងសុខដុមភាវូបនីយកម្មនៃកិច្ចសហប្រតិបត្តិការ

១០-ផ្នែករដ្ឋបាល។

**មាត្រា៥ .-**

គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកទំនាក់ទំនងសាធារណៈ និងការជំរុញគម្រោងវិនិយោគឯកជន

២- ផ្នែកវិភាគគម្រោង និងការលើកទឹកចិត្ត

៣- ផ្នែកវាយតម្លៃខាងបរិស្ថាន

៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង

៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៦- ផ្នែកនីតិកម្ម និងច្បាប់វិនិយោគ

៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ

៨- ផ្នែករដ្ឋបាល។

**មាត្រា៦ .-**

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ និងផែនការ

២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង

៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង

៤- ផ្នែករដ្ឋបាល។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" រួមមាន "ផ្នែកគាំទ្រ" ចំនួន ៤៖

១- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ

២- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ

៣- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក

៤- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

**មាត្រា៨ .-**

ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូបជាជំនួយការ។

**មាត្រា៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ។

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ៖

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

## ជំពូកទី ២
## សមត្ថកិច្ច និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ៖

១- ជាសេនាធិការ និងជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

២- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើឱ្យគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។

៣- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។

៤- តម្រង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា។

៥- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ។

៦- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ គម្រោងវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា១១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ៖

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា១២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន។

**មាត្រា១៣ .-**

ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទងជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍។

៣- កៀរគរ និងវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តបណ្តាគោលដៅអាទិភាព ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ។

៤- ដឹកនាំផ្ទាល់កិច្ចការដែលពាក់ព័ន្ធនឹងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះ។

៦- រៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំកម្រិតគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ ដូចជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និង "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ។

៧- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមវិស័យសម្រាប់អភិវឌ្ឍន៍កម្ពុជា។

៨- ចូលរួមគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា។

៩- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីទទួល និង/ឬបែងចែកហិរញ្ញប្បទានទាំងនោះ។

១០-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

**មាត្រា១៤ .-**

ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្ដាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" ជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្គួចការទូតផ្លូវការ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ព្រមទាំងទទួលបន្ទុកចៀរគរ និងគ្រប់គ្រងដោយផ្ទាល់នូវហិរញ្ញប្បទានជាការខ្ចី និងជំនួយបច្ចេកទេសដែលមានការពាក់ព័ន្ធ។

៥- ក្រសួងជំនាញជាអ្នករៀបចំផែនការអភិវឌ្ឍន៍ និងគម្រោងវិនិយោគសាធារណៈតាមវិស័យដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ, ជាមួយ "ក.អ.ក" និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៥ .-**

ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួន ខាងការវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៦ .-**

ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តកម្មវិធី និង/ឬគម្រោងស្របតាមសមត្ថកិច្ចរៀងៗខ្លួនដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ។

**មាត្រា១៧ .-**

ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា៣ នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ "ការប្រណាំងប្រជែងដណ្ដើមឈ្នះ" លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចឱ្យបាននូវទស្សនៈនេះដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជា "សាជីវកម្មកម្ពុជា"។ សហការ

ជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកវិនិយោគ តាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានាដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

**មាត្រា១៨ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជនដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគម្រោងខ្លះមិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជនដែល "ក.អ.ក" បានផ្តល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២១ .-**

ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាពរដ្ឋ ឯកជនចម្រុះរដ្ឋ និងឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចឱ្យបាននូវទស្សនៈនេះ ដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានាដែលមានប្រសិទ្ធភាព និងឆាប់រហ័ស។

៤- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលជាអាទិភាពរបស់រាជ-រដ្ឋាភិបាល។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិនានា និងដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរនានា និងការធ្វើអធិការកិច្ចចំពោះតំបន់សេដ្ឋកិច្ចពិសេស។

៧- ចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស និងតម្រង់ទិសការងារវិនិយោគតំបន់។

**មាត្រា២២ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

៣- "ក.អ.ក" សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### មាត្រា២៣ .-

ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក"

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងនៃអង្គប្រជុំពេញអង្គរបស់ "ក.អ.ក"

៣- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"

៤- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ "ក.អ.ក"។

### មាត្រា២៤ .-

នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់លើការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និងការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ។

### មាត្រា២៥ .-

អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន "ក.អ.ក" អវត្តមាន។

២- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "ក.អ.ក"។

៣- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសម្របសម្រួលជាមួយប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។

៤- ទទួលបន្ទុកសម្របសម្រួលការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ជាមួយតួអង្គអភិវឌ្ឍន៍ដោយសហការជិតស្និទ្ធជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

៥- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៅក្នុងដែនសមត្ថកិច្ចនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

៦- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ ជំរុញការវិនិយោគឯកជន និងកិច្ចការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយការងារអភិវឌ្ឍន៍វិស័យឯកជន យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រនេះ។

៧- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយ "គ.វ.ក" ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" លើការងារវិនិយោគឯកជន។

៨- ទទួលបន្ទុកពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជនដែលមានលក្ខណៈសាមញ្ញ ដូចជា រោងចក្រកាត់ដេរ រោងចក្រស្បែកជើង និងឧស្សាហកម្មគាំទ្រជាដើម ព្រមទាំងបណ្តាគម្រោងដែលមិនទាមទារការលើកទឹកចិត្តផងដែរ។

៩- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ានដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន។

១០-ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង "ក.អ.ក" ជាមួយនឹងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល។

១១-បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៦ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក"។

២- ទទួលបន្ទុកសម្របសម្រួល និងតាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាសេនាធិការបច្ចេកទេសឱ្យ "ក.អ.ក" ក្នុងការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

៤- រៀបចំកម្មវិធីការងាររបស់ "ក.អ.ក" និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៥- សម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូន គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគឯកជន ។

៧- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន"។

៨- បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៧ .-**

អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.ជ.នា"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍។

៣- រៀបចំ និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងជាអ្នកដឹកនាំរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ។

៤- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" និងយន្តការពិគ្រោះយោបល់ដទៃទៀត។

៥- ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ និងចុះហត្ថលេខាលើកម្មវិធីសហប្រតិបត្តិការឥតសំណងទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍។

៦- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៧- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៨- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេចមុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៩- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៨ .-**

អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.វ.ក"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការវិនិយោគឯកជន។

៣- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៥- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៦- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

៧- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៩ .-**

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.ស.ព"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ"។

៤- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំពេញអង្គរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៥- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងការវិវត្តនៃគម្រោងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលមានការពាក់ព័ន្ធ ហើយធ្វើ

របាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់។

៦- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល។

៧- បំពេញការងារដទៃទៀត ដែលទាក់ទងនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា៣០ .-**

សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយ កម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តទាំងខាងផ្នែកសាធារណៈទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**មាត្រា៣១ .-**

ក្នុងករណីចាំបាច់ប្រធាន "ក.អ.ក" អាចកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ឬប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"។

**មាត្រា៣២ .-**

ការប្រព្រឹត្តទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៣ .-**

ការអនុវត្តការងារនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគឯកជន និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ដូចខាងក្រោម៖

ទី១- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា៖

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។ មន្ត្រីរូបនោះត្រូវៈ

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្ថិតរមូតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ជ.នា" ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ជ.នា" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង-អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី២- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជាៈ

ក-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការវិនិយោគកម្ពុជា។ មន្ត្រីរូបនោះត្រូវៈ

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន

- ស្ថិតរមូតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.វ.ក" ចំពោះតែកិច្ចការវិនិយោគឯកជនណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.វ.ក" មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៣-សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា៖

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួង រ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្និតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្និតរមូតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ស.ព" ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ស.ព" មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ដែលត្រូវមន្ត្រីពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៤- ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងព័ត៌មានផ្សេងៗពីអគ្គលេខាធិការ "គ.ជ.នា" អគ្គលេខាធិការ "គ.វ.ក" អគ្គលេខាធិការ "គ.ស.ព" មក អគ្គលេខាធិការ "ក.អ.ក" ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

**មាត្រា៣៤ .-**

សេចក្តីលម្អិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៥ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និងមានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន។ ការគ្រប់គ្រងចំណូល និងចំណាយថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៣៦ .-**

អនុក្រឹត្យនេះ ជំនួសអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣។

**មាត្រា៣៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈ

អភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលគ្រប់ខេត្តទាំងអស់ និងសមាសភាព ដូចមានក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ